ព្រឹត្តិបត្រព័ត៌មាន

# ការប្រែប្រួលអាកាសធាតុ

#៨

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
នាយកដ្ឋានប្រែប្រួលអាកាសធាតុ

មករា-មីនា
២០១៧

## គោលនយោបាយប្រែប្រួលអាកាសធាតុនិងការអនុវត្ត

### កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនកម្ពុជានៅតាមជនបទ

ដើម្បីកែលម្អរបរចិញ្ចឹមជីវិតរបស់ប្រជាជនធន់នឹងការប្រែប្រួលអាកាសធាតុក្នុងរយៈពេលវែង គឺត្រូវកែលម្អការគ្រប់គ្រងនិងប្រើប្រាស់ធនធានទឹកដែលមានស្រាប់នៅមូលដ្ឋានសម្រាប់កសិកម្ម។ គម្រោង "កាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិនិងការអនុវត្តសកម្មភាពអាទិភាព" ហៅកាត់ថា គម្រោងSRL កំពុងធ្វើកិច្ចការខាងលើ ដោយផ្តោតជាពិសេសលើគ្រួសារក្រីក្រ មានដីតិចតួចឬគ្មានដី និង/ឬស្ត្រីជាមេគ្រួសារ។

គម្រោងនេះអនុវត្តដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព សម្របសម្រួលជាមួយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)។ ចាប់ពីខែកក្កដា ឆ្នាំ២០១៥ រហូតខែធ្នូ ឆ្នាំ២០១៩ គម្រោងនេះនឹងអនុវត្តនៅក្នុងឃុំចំនួន៨៩ក្នុងស្រុកចំនួន១០ នៃខេត្តសៀមរាប និងកំពង់ធំ ដើម្បីកែលម្អប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងរបរចិញ្ចឹមជីវិតនៅតំបន់ជនបទ តាមរយៈការរៀបចំផែនការ ថវិកា និងការអនុវត្តសកម្មភាពដែលគិតគូរពីអាកាសធាតុ។

គោលដៅរបស់គម្រោងSRL នឹងសម្រេចបានលទ្ធផលចម្បងចំនួនបី៖

- ពង្រឹងផែនការប្រែប្រួលអាកាសធាតុ ថវិកា និងការអនុវត្តនៅថ្នាក់ក្រោមជាតិ ដោយធ្វើការគាំទ្រការបញ្ជ្រាបវិធានការបន្សាំទៅក្នុងផែនការនិងកម្មវិធីវិនិយោគមានស្រាប់របស់ស្រុកចំនួន១០និងឃុំនានានៃស្រុកទាំងនោះ

តទៅទំព័រទី២



ទីជម្រាលខ្នាតតូចសម្រាប់បង្កើនភាពធន់ទៅនឹងអាកាសធាតុ ខេត្តសៀមរាប

## កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

### របាយការណ៍វាយតម្លៃលើកទី៦របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុកំពុងរៀបចំ

សប្តាហ៍ទីមួយនៃខែឧសភា ប្រទេសជាសមាជិកនៃក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ(IPCC) បានជួបប្រជុំពិភាក្សាអំពីចំណុចផ្តោតនៃការរៀបចំរបាយការណ៍វាយតម្លៃលើកទី៦របស់IPCC នៅទីក្រុងអាឌីសអាបាបា ប្រទេសអេត្យូពី។ ទម្រង់រួមនៃរបាយការណ៍នេះ (រួមបញ្ចូលទាំងធាតុចូលរបស់ក្រុមការងារចំនួន៣ : វិទ្យាសាស្ត្ររូប, ផលប៉ះពាល់ បន្សាំ និងភាពងាយរងគ្រោះ, និងការកាត់បន្ថយ) នឹងត្រូវអនុម័តនៅខែតុលាខាងមុខ ប៉ុន្តែរបាយការណ៍វាយតម្លៃលើកទី៦នេះនឹងត្រូវបញ្ចប់នៅរយៈពេល៥ឆ្នាំខាងមុខ ពោលគឺនៅឆមាសទីមួយឆ្នាំ២០២២។

របាយការណ៍វាយតម្លៃរបស់IPCC គឺជាកិច្ចការសំខាន់ ដោយរួមបញ្ចូលទាំងការពិនិត្យមើលឯកសារវិទ្យាសាស្ត្រជាច្រើនពាន់ប្រភេទចេញផ្សាយរៀងរាល់ឆ្នាំពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ បច្ចេកទេស និងគោលនយោបាយ ព្រមទាំងចង្អុលបង្ហាញដល់អ្នករៀបចំគោលនយោបាយ ថាតើវិទ្យាសាស្ត្រ

តទៅទំព័រទី៣

### មាតិកាព័ត៌មាន

គោលនយោបាយប្រែប្រួលអាកាសធាតុនិងការអនុវត្ត
- កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនកម្ពុជានៅតាមជនបទ ............ ១
- ប្រព័ន្ធដាំដុះដោយប្រើដំណាំគម្របដីនិងមិនភ្ជួរដី៖ តើការអនុវត្តបច្ចេកទេសនេះនៅមូលដ្ឋាននឹងផ្តល់ព័ត៌មានសម្រាប់គោលនយោបាយជាតិយ៉ាងដូចម្តេច?............ ២
- កិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធអំពីក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ............ ៣

កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ
- របាយការណ៍វាយតម្លៃលើកទី៦របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុកំពុងរៀបចំ ............ ១

សម្លេងពីមូលដ្ឋាន ............ ៤
ការចេញផ្សាយបន្ទាប់ ............ ៤
ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ ............ ៤

### ចំណាប់អារម្មណ៍របស់និពន្ធនាយក

*សូមគោរពប្រិយមិត្តអ្នកអាន យើងខ្ញុំសូមស្វាគមន៍ចំពោះការអានព្រឹត្តិបត្រព័ត៌មានការប្រែប្រួលអាកាសធាតុ។ ព្រឹត្តិបត្រព័ត៌មាននេះចេញផ្សាយរៀងរាល់ត្រីមាស ដើម្បីឆ្លុះបញ្ចាំងអំពីការអភិវឌ្ឍគោលនយោបាយអាកាសធាតុថ្មីៗនៅកម្ពុជា ព្រមទាំងបច្ចុប្បន្នភាពការងារជាច្រើនដែលអនុវត្តក្រោមអណត្តិនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ដោយឡែកក្នុងត្រីមាសទី២និងទី៤នៃឆ្នាំនីមួយៗ យើងនឹងបន្ថែមការចែករំលែកបទពិសោធន៍សំខាន់ៗដែលអនុវត្តដោយអង្គការដៃគូនិងសហគមន៍នានាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ យើងខ្ញុំសង្ឃឹមថាប្រិយមិត្តអ្នកអាននឹងផ្តល់ធាតុចូលដូចជាការផ្តល់មេរៀនល្អៗនិងករណីសិក្សានានាដែលនាំឱ្យព្រឹត្តិបត្រនេះជោគជ័យ៕*

### ក្រុមការងាររៀបចំ និងត្រួតពិនិត្យ

*ព្រឹត្តិបត្រព័ត៌មាននេះ ត្រូវបានរៀបចំកែសម្រួល និងផលិតដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានជំនួយបច្ចេកទេសពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា៕*

# គោលនយោបាយប្រែប្រួលអាកាសធាតុនិងការអនុវត្ត

## កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនកម្ពុជា ...

*តពីទំព័រទី១*

តាមរយៈការអភិវឌ្ឍសមត្ថភាពបច្ចេកទេសផ្នែកផ្សព្វផ្សាយអំពីកសិកម្មគិតគូរអាកាសធាតុ និងផ្នែករៀបចំផែនការនិងអនុវត្តការងារវិនិយោគហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុ។

- ធ្វើឱ្យប្រសើរឡើងនូវភាពធន់នៃជីវភាពរស់នៅរបស់ប្រជាជនងាយរងគ្រោះដោយការប្រែប្រួលរបបទឹកភ្លៀង ទឹកជំនន់ និងភាពរាំងស្ងួត តាមរយៈការវិនិយោគហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹកខ្នាតតូចដែលជួយឱ្យកសិករទប់នឹងការធ្លាក់ភ្លៀងរស្សាដែលមិនអាចព្យាករណ៍ ហើយធ្វើឱ្យផលិតកម្មកសិកម្មកាន់តែមានភាពធន់។ ក្រុមស្ត្រីក្រីក្រ និងងាយរងគ្រោះ នឹងទទួលការគាំទសម្រាប់បង្កើតមុខរបរចិញ្ចឹមជីវិតដែលទាមទារដីទំហំតូចប៉ុណ្ណោះ និងទទួលការគាំទ្របន្ថែមផ្នែកកសាងមូលធនសង្គម។
- បានធ្វើឱ្យប្រសើរនូវបរិយាកាសទាក់ទាញជំនួយ និងពង្រីកការគ្រប់គ្រងហិរញ្ញវត្ថុបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់ក្រោមជាតិ ដើម្បីកសាងភាពធន់នៃជីវភាពរស់នៅតាមជនបទ ដោយកែលម្អប្រព័ន្ធវាយតម្លៃការងាររដ្ឋាភិបាលថ្នាក់ក្រោមជាតិលើផ្នែកបន្សាំ ដោយប្រើប្រាស់ជំនួយឥតសំណងសម្រាប់ធន់នឹងអាកាសធាតុផ្អែកលើលទ្ធផល (ដើម្បីផ្តល់ថវិកាបដិភាគ សម្រាប់វិនិយោគហេដ្ឋារចនាសម្ព័ន្ធ) ពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ តាមដានវាយតម្លៃ ព្រមទាំងលើកផែនការកែលម្អសមត្ថភាពនិងលទ្ធផលក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។


*ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ប្រកាសបើកដំណើរការគម្រោងSRL នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ នៅខេត្តសៀមរាប*

សិក្ខាសាលាបើកដំណើរការគម្រោងSRLជាផ្លូវការបានរៀបចំឡើងនៅខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសរុបចំនួន៨០នាក់ តំណាងស្ថាប័នថ្នាក់ជាតិក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន៕

## ប្រព័ន្ធដាំដុះដោយប្រើដំណាំគម្របដីនិងមិនភ្ជួរដី៖ តើការអនុវត្តបច្ចេកទេសនេះនៅមូលដ្ឋាននឹងផ្តល់ព័ត៌មានសម្រាប់គោលនយោបាយជាតិយ៉ាងដូចម្តេច ?

**តើប្រព័ន្ធដាំដុះដោយប្រើដំណាំគម្របដីនិងមិនភ្ជួរដី ជាអ្វី ?**

ប្រព័ន្ធដាំដុះដោយប្រើដំណាំគម្របដីនិងមិនភ្ជួរដី( Direct Seeding Much-based Cropping: DMC) ប្រើប្រាស់គោលការណ៍បច្ចេកទេសនៃកសិកម្មអភិរក្សចំនួន៣ : រំខានដីតិចតួច មានគម្របដីជាប្រចាំ និងពិពិធកម្មមុខដំណាំ។ ប្រព័ន្ធនេះ ជួយឱ្យដំណាំគម្របដីមានមុខងារខុសគ្នា និងប្រើប្រភេទដំណាំខុសគ្នាសមស្រប ដើម្បីកែលម្អដំណើរការជីវសាស្ត្រនិងប្រព័ន្ធផលិតកម្មទាំងមូល រួមចំណែកបង្កើនភាពរស់នៃដី។ ប្រព័ន្ធនេះប្រើប្រាស់ដំណាំច្រើនប្រភេទតាមរដូវកាលនិងទីកន្លែងជាក់លាក់ ពីកម្រិតចម្ការដល់តំបន់ទេសភាព ដើម្បីបង្កើនជីជាតិដីសម្រាប់ដំណាំ កាត់បន្ថយការបាត់បង់ទឹកនិងជីជាតិ ពង្រីកវត្តមានសារពាង្គកាយរស់របស់ដី និងបង្កើនអត្ថប្រយោជន៍ទៅវិញទៅមករបស់កសិប្រព័ន្ធអេកូឡូស៊ីតាមរយៈអន្តរកម្មជីវសាស្ត្រនិងភាពបំពេញគ្នា។



*គោលការណ៍បច្ចេកទេសនៃប្រព័ន្ធដាំដុះដោយប្រើដំណាំគម្របដីនិងមិនភ្ជួរដី*

ទម្លាប់នៃការអនុវត្តកសិកម្មអភិរក្ស ច្រើននាំមកនូវផលប៉ះពាល់អវិជ្ជមានមកលើធនធានធម្មជាតិ ដូចជា ដី ទឹក និងជីវៈចម្រុះ។ ភាពរាំងស្ងួតកាន់តែធ្ងន់ធ្ងរនិងញឹកញាប់ បណ្តាលឱ្យកសិករតូចតាចនៅតំបន់កសិកម្មពឹងទឹកភ្លៀង ដែលមានសរុបជាង៨០% នៃផ្ទៃដីដាំដុះសរុបនៅកម្ពុជា កាន់តែប្រឈមនឹងភាពងាយរងគ្រោះ។ ប្រព័ន្ធDMCត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះដោយបង្កើនភាពធន់នៃដី និងបង្កើនសមត្ថភាពបន្សាំរបស់កសិករតូចតាចចំពោះកង្វះទឹកនិងភាពរាំងស្ងួត។

លទ្ធផលនៃការពិសោធនៅកម្ពុជា បង្ហាញថាប្រព័ន្ធនេះគឺជាវិធានការបន្សាំមួយប្រកបដោយប្រសិទ្ធភាពក្នុងការបង្កើនសមត្ថភាពរក្សាសំណើមដីនិងកាត់បន្ថយរំហួត។ លើសពីនេះ ប្រព័ន្ធនេះអាចកាត់បន្ថយហានិភ័យអាកាសធាតុ ដោយផ្តល់មកវិញនូវជម្រើសបត់បែនសម្រាប់កសិករក្នុងការដាំដំណាំចម្បង ដូចជា ដំឡូងមី និងស្រូវ ដែលបន្តដោយជម្រើសដំណាំបន្ទាប់បន្សំដែលមានវដ្តលូតលាស់ខ្លីខុសគ្នា។ ប្រព័ន្ធនេះក៏រួមចំណែកដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយសារការឈប់ភ្ជួរនិងរាស់ដី ហើយបន្ទាប់មកបង្កើនសារធាតុសរីរាង្គក្នុងដី (រួមបញ្ចូលទាំង


*ការប្រៀបធៀបកសិកម្មអភិរក្សនិងប្រព័ន្ធDMC បង្ហាញថាប្រព័ន្ធDMC (ទី២និង៣ ពីឆ្វេង) មានសារធាតុសរីរាង្គនិងស្រូបទុកកាបូនច្រើនជាង*

កាបូនសរីរាង្គដី) នាំឱ្យបង្កើនការស្រូបទុកកាបូន។

គម្រោងប្រពលវប្បកម្មអេកូឡូស៊ីដីនិងមុខងារកម្មប្រព័ន្ធអេកូឡូស៊ី (EISOFUN) ដែលអនុវត្តដោយអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជានិងគាំទ្រពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា(CCCA) មានគោលដៅបង្កើតចំណេះដឹងវិទ្យាសាស្ត្រអំពីសេវាប្រព័ន្ធអេកូឡូស៊ីដី ដែលអាចជួយអ្នករៀបចំគោលនយោបាយអាចរៀបចំគោលនយោបាយនវានុវត្តន៍និងយន្តការសមស្រប សម្រាប់ជួយកសិករនិងបង្កើនការផ្សព្វផ្សាយប្រព័ន្ធដាំដុះនេះ។ ដៃគូគម្រោងEISOFUN បានគូសបញ្ជាក់ថាគម្រោងនេះជាផ្នែកមួយនៃការរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយជំរុញកសិកម្មឆ្លាតខាងអាកាសធាតុនិងពង្រឹងការអភិវឌ្ឍទម្លាប់កសិកម្មច្នៃប្រឌិតតាមបែបធម្មជាតិ សំដៅបង្កើនភាពបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ លទ្ធផលនៃការអនុវត្តគម្រោងនឹងរួមចំណែកផ្តល់ជាព័ត៌មានសម្រាប់កម្មវិធីរបស់ក្រសួងកសិកម្ម និងគោលនយោបាយជាតិរបស់ក្រសួងកសិកម្ម (ដូចជា ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម) តាមរយៈទិវាស្រែកសិករ វេទិកាពហុអ្នកពាក់ព័ន្ធ ឯកសារសង្ខេបគោលនយោបាយ វេទិកាចែករំលែក និងផ្សព្វផ្សាយចំណេះដឹង៕

## កិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធអំពីក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ

ដោយមានកិច្ចសហប្រតិបត្តិការនិងជំនួយហិរញ្ញវត្ថុពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ(USAID) កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់(GIZ) កំពុងអនុវត្តកម្មវិធីត្រៀមហិរញ្ញវត្ថុអាកាសធាតុ ដើម្បីគាំទ្រផ្នែកបច្ចេកទេសអនុវត្តផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុដល់នាយកដ្ឋានប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំ គឺជាសមិទ្ធផលសំខាន់មួយនៃកម្មវិធីត្រៀមហិរញ្ញវត្ថុអាកាសធាតុ ដើម្បីបង្កើនល្បឿនភាពត្រៀមនៃហិរញ្ញវត្ថុអាកាសធាតុនៅកម្ពុជា។

នៅខែកុម្ភៈ ឆ្នាំ២០១៧ សិក្ខាសាលាពិគ្រោះយោបល់ដែលមានអ្នកចូលរួមសរុប៤៤រូប តំណាងក្រសួងស្ថាប័ននិងដៃគូអភិវឌ្ឍចំនួន២៣ស្ថាប័ន រួមគ្នាពិភាក្សានិងផ្តល់យោបល់លើសេចក្តីព្រាងក្របខណ្ឌហិរញ្ញប្បទាននេះនិងផែនការអនុវត្ត និងបានវិភាគសកម្មភាពអាទិភាពចំនួន៤០ដែលស្រង់ពីសកម្មភាពពុំទាន់ទទួលមូលនិធិចំនួន១៤៨នៅក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួងស្ថាប័នដែលងាយរងផលប៉ះពាល់ដោយសារអាកាសធាតុ។ លទ្ធផលនៃការពិភាក្សាបានផ្តល់ព័ត៌មានសម្រាប់រៀបចំខ្លឹមសារនៃក្របខណ្ឌ ដូចខាងក្រោម៖

- ផែនការអនុវត្តក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំ នឹងស្នើអនុសាសន៍សម្រាប់រយៈពេលខ្លី មធ្យម និងវែង ដោយរួមបញ្ចូលបញ្ហានានា ដូចជា ការរៀបចំនិងលំដាប់លំដោយនៃសកម្មភាពសំដៅតម្រង់ទិសសកម្មភាពអាទិភាពស្វែងរកប្រភពមូលនិធិដែលមានសក្តានុពល។
- សកម្មភាពអាទិភាពប្រមាណ៤០ ត្រូវបានចាត់ថ្នាក់ជា "ដំណាក់កាលជិតអនុវត្ត" ឬ រៀបនឹងត្រៀមទទួលហិរញ្ញប្បទានអាកាសធាតុ។



សិក្ខាសាលាពិគ្រោះយោបល់អំពីសេចក្តីព្រាងក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំ និងផែនការអនុវត្ត ខែកុម្ភៈ ឆ្នាំ២០១៧ នៅភ្នំពេញ

- សកម្មភាពមួយចំនួនទាមទារឱ្យមានពេលវេលានិងកិច្ចប្រឹងប្រែងមុននឹងអាចត្រៀមដាក់ពាក្យសុំទៅប្រភពមូលនិធិនានា ត្រូវចាត់ជា "ដំណាក់កាលរៀបចំ"។ សកម្មភាពបន្ថែមជាអន្តរវិស័យ ត្រូវចាត់ជា "ការរួមចំណែកបង្កើតបរិយាកាសអំណោយផលសម្រាប់ផែនការសកម្មភាពជាតិ"។

ដើម្បីបំពេញបន្ថែមលើផែនការអនុវត្តហិរញ្ញប្បទានផែនការជាតិបន្សាំ ក្របខណ្ឌហិរញ្ញប្បទាននេះបានបញ្ចូលការវិភាគពិស្តារអំពីជម្រើសមូលនិធិអាកាសធាតុអន្តរជាតិសម្រាប់សកម្មភាពបន្សាំអាទិភាព ក៏ដូចជា ការពិនិត្យលទ្ធផលសិក្សាកន្លងមក ដូចជា ការវាយតម្លៃតម្រូវការហិរញ្ញប្បទានសម្រាប់សកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការពិនិត្យលើការចំណាយនិងថវិកាជាតិ ការសិក្សាកាលានុវត្តភាពវិនិយោគនៃវិស័យឯកជន៕

# កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

## របាយការណ៍វាយតម្លៃលើកទី៦របស់ក្រុមការងារអន្តររដ្ឋាភិបាល ...

*តពីទំព័រទី១*

បានដឹងនិងមិនដឹងអ្វីខ្លះអំពីហានិភ័យទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ មកទល់បច្ចុប្បន្ន របាយការណ៍ទាំងនេះបានបង្ហាញភស្តុតាងឥទ្ធិពលយ៉ាងច្រើនមកលើការរៀបចំរបៀបវារៈគោលនយោបាយសាកលលោកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ : ការចេញផ្សាយរបាយការណ៍វាយតម្លៃលើកទី៥ឆ្នាំ២០១៤បានផ្តល់ភស្តុតាងវិទ្យាសាស្រ្តសំខាន់ៗដល់ការរៀបចំកិច្ចព្រមព្រៀងទីក្រុងប៉ារីស គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងក្របខណ្ឌសេនដាយសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ហើយក៏បានជួយប្រទេសនានាដូចជាកម្ពុជា ក្នុងការទទួលបានព័ត៌មានវិទ្យាសាស្រ្តសម្រាប់រៀបចំគោលនយោបាយអាកាសធាតុឱ្យកាន់តែមានប្រសិទ្ធភាព។ ឧទាហរណ៍ ព័ត៌មានក្នុងរបាយការណ៍




*ប្រតិភូជួបប្រជុំនៅការិយាល័យកណ្តាលនៃអង្គការ UNEP ក្នុងទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា ដើម្បីការចាប់ផ្តើមកិច្ចប្រជុំ IPCC-43 ឆ្នាំ២០១៦*




*វដ្តនៃការវាយតម្លៃរបាយការណ៍លើកទី៦របស់IPCC*

លើកទី៥ កំពុងត្រូវបានប្រើប្រាស់ដើម្បីរៀបចំការព្យាករអាកាសធាតុបំព្រួញមាត្រដ្ឋានសម្រាប់តំបន់មេគង្គនិងសម្រាប់កម្ពុជាទៅអនាគត។

របាយការណ៍លើកទី៦និងរបាយការណ៍ពិសេសរបស់IPPC នឹងកំណត់គោលដៅថ្មីៗអំពីអាកាសធាតុនៅកម្រិតនយោបាយឱ្យមានការឯកភាពព្រមទាំងជួយបង្កើតយន្តការឆ្លើយតបចាំបាច់។ តាមកំណត់សម្គាល់ក្នុងសេចក្តីប្រកាសព័ត៌មានថ្មីៗ IPCCបានសម្រេចផ្តោតការយកចិត្តទុកដាក់ជាពិសេសលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើទីក្រុងព្រមទាំងបញ្ហាប្រឈមនិងកាលានុវត្តភាពនៃបន្សាំនិងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ក្នុងទីក្រុងនោះ។ ធាតុចូលរបស់កម្ពុជានៅក្នុងការរៀបចំរបាយការណ៍ទាំងនេះ នឹងបញ្ចូលទៅក្នុងរបៀបវារៈរបស់IPCCសម្រាប់អភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ដែលនាំឱ្យមានការកៀគរការគាំទ្រពីពិភពលោកស្វែងរកដំណោះស្រាយ។ ព័ត៌មានបន្ថែមអំពីរបាយការណ៍ IPCC មាននៅក្នុងwww.ipcc.ch៕

## ការចេញផ្សាយបន្ទាប់...

### សម្លេងពីមូលដ្ឋាន



#### ខេត្តកែបពង្រឹងសមត្ថភាពបែបណាដើម្បីទប់ទល់នឹងហានិភ័យអាកាសធាតុដែលកើន

ភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលបានព្យាករ កាន់តែកើនឡើង ឆ្នេរសមុទ្រនៅក្នុងខេត្តកែបដែលស្ថិតនៅភាគខាងត្បូងនៃប្រទេសមានការព្រួយបារម្ភកាន់តែខ្លាំងអំពីអនាគតរបស់ពួកគេ។ ពួកគេដឹងអំពីការប្រឈមនឹងហានិភ័យអាកាសធាតុ ដូចជា ការកញ្ជ្រោលនៃព្យុះ ការជ្រាបចូលនៃទឹកប្រៃ និងគ្រោះរាំងស្ងួត។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត(PCDM)ដែលមានសមាជិកនៅថ្នាក់ខេត្ត ស្រុក និងឃុំ បានធ្វើការជាមួយមន្ទីរពាក់ព័ន្ធក្នុងខេត្ត ដើម្បីបានពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការឆ្លើយតបនឹងហានិភ័យអាកាសធាតុសំខាន់ៗសម្រាប់ខេត្តរបស់ខ្លួន។ លោកស្រី កែវ នី សមាជិកមួយរូបនៃPCDM និងជាអនុប្រធានមន្ទីរកិច្ចការនារីខេត្ត បានចូលរួមក្នុងការងារនេះ ហើយគាត់នឹងបង្ហាញបទពិសោធន៍នៃការអភិវឌ្ឍសមត្ថភាពដើម្បីដោះស្រាយហានិភ័យនៃការប្រែប្រួលអាកាសធាតុ នៅក្នុងព្រឹត្តិបត្រព័ត៌មានលេខបន្ទាប់។

### សម្លេងពីមូលដ្ឋាន



#### បង្កើនលទ្ធភាពទទួលបានទឹក លើកកម្ពស់សុខភាព និងអនាម័យ

ដោយសារតែលទ្ធភាពទទួលបានទឹកនិងអនាម័យនៅតំបន់ឆ្នេរមានតិច ទាំងក្នុងរដូវវស្សា និងរដូវប្រាំងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានសម្រេចសាងសង់ស្ថានីយផលិតទឹកស្អាតនៅខេត្តកំពត និងកែបដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហគមន៍។ លើសពីនេះ ស្រះដែលមានស្រាប់ ក៏ត្រូវបានស្តារឡើងវិញ និងកំពុងផ្គត់ផ្គង់ទឹកដល់ស្ថានីយផលិតទឹកស្អាត ក៏ដូចជា ផ្គត់ផ្គង់ទឹកសម្រាប់ប្រើប្រាស់តាមគ្រួសារ សួនដំណាំតូចៗ និងការចិញ្ចឹមសត្វដោយផ្ទាល់។ អ្នកទទួលផលពីការងារនេះ គឺជាប្រជាជនដែលរស់នៅក្នុងឃុំចំនួន៥នៃខេត្តកែបនិងកំពត រួមបញ្ចូលទាំងគ្រួសារស្ត្រីជាមេគ្រួសារ ជាពិសេស ប្រជាជនក្រីក្របំផុតនិងស្ត្រីមេម៉ាយ។ ឃុំទាំងនេះត្រូវបានជ្រើសរើសជាឃុំគោលដៅនៃការវិនិយោគ ដោយសារមានភាពងាយរងគ្រោះខ្លាំងនៃការប្រែប្រួលអាកាសធាតុ។ លោកអ្នកនឹងដឹងថាតើទឹកស្អាតដែលស្ថានីយនេះផលិតបាន ក៏ដូចជាស្រះដែលបានស្តារ អាចឆ្លើយតបនឹងតម្រូវការរបស់សហគមន៍យ៉ាងដូចម្តេចនៅក្នុងព្រឹត្តិបត្រព័ត៌មានលេខបន្ទាប់។

## ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ

### ក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ

ក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដូចមានក្នុងអត្ថបទទំព័រទី៣នៃព្រឹត្តិបត្រនេះ នឹងបោះពុម្ពផ្សាយឆាប់ៗខាងមុខដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ឯកសារនេះបង្ហាញពីការវិភាគហិរញ្ញប្បទានពហុទិដ្ឋភាព(ការស្វែងយល់ពីតម្រូវការ គម្លាតបច្ចុប្បន្ន ជម្រើសនៃមូលនិធិក្នុងប្រទេសនិងអន្តរជាតិ) និងផ្តល់នូវផែនការអនុវត្តសម្រាប់ក្របខណ្ឌនេះ។ ផែនការអនុវត្តហិរញ្ញប្បទានផែនការជាតិបន្សាំ បង្ហាញសកម្មភាពសម្រាប់រយៈពេលខ្លីនិងមធ្យម និងស្តែងឱ្យឃើញ និងកៀរគរធនធានសម្រាប់សកម្មភាពអាទិភាពបន្សាំនឹងអាកាសធាតុចំនួន៤០ ដែលបានជ្រើសរើសចេញពីសកម្មភាពសរុបចំនួន១៤៨ នៅក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យដែលពុំទាន់មានមូលនិធិគាំទ្រ។ ឯកសារនេះនឹងអាចជួយបង្កើនល្បឿននៃដំណើរការអនុវត្តផែនការជាតិបន្សាំនៅកម្ពុជា ដើម្បីរួមចំណែកឆ្លើយតបនឹងបញ្ហាអាកាសធាតុជារួមនៅក្នុងប្រទេស។

## ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ

| | |
|---|---|
| មេសា | ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសទ្ទានុក្រមការប្រែប្រួលអាកាសធាតុ |
| ឧសភា | សិក្ខាសាលាបង្កើនការយល់ដឹងអំពីក្របខណ្ឌ SPCR |
| ឧសភា | កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីផែនការគោលយេនឌ័រ និងឯកសារបណ្តុះបណ្តាល |
| ឧសភា | វគ្គបណ្តុះបណ្តាលសង្គមស៊ីវិលស្តីពីភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅតំបន់ទីក្រុង |
| មិថុនា | វគ្គបណ្តុះបណ្តាលលើកទី២ស្តីពីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) |
| ឧសភា | សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់យុវជននៅខេត្តស្វាយរៀង |
| មិថុនា | កិច្ចប្រជុំក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ(CCTWG) ស្តីពីការត្រួតពិនិត្យនិងវាយតម្លៃការប្រែប្រួលអាកាសធាតុ |
| មិថុនា | វគ្គបណ្តុះបណ្តាលសម្រាប់ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការថ្នាក់ក្រោមជាតិ |
| មិថុនា | សិក្ខាសាលាដៃគូពាក់ព័ន្ធស្តីពីការត្រួតពិនិត្យនិងវាយតម្លៃបន្សាំ |
| មិថុនា | ពិធីប្រកាសដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំសម្រាប់បន្សាំ និងករណីសិក្សាអំពីភាពធន់នឹងអាកាសធាតុ |
| មិថុនា | សិក្ខាសាលាចែករំលែកចំណេះដឹងអនុវត្តសកម្មភាពអាទិភាពប្រែប្រួលអាកាសធាតុរបស់ស្ថាប័នទទួលជំនួយពី CCCA |
| មិថុនា | កិច្ចប្រជុំក្រុមការងារCCTWG ជាមួយដៃគូអភិវឌ្ឍ |

*សម្រាប់ព័ត៌មានទាក់ទងនឹងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឬឯកសារបោះពុម្ពថ្មីៗ សូមតាមដានគេហទំព័រ www.camclimate.org.kh*


**គាំទ្រដោយ**

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា
CAMBODIA CLIMATE CHANGE ALLIANCE

Implemented by: Ministry of Environment
Supported by: European Union, UNDP (Empowered lives. Resilient nations.), SWEDEN



**ទំនាក់ទំនង**

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
ស្ថិតក្នុងក្រសួងបរិស្ថាន អគារមរតកតេជោ ដីឡូត៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ (+៨៥៥-២៣) ៦៣៣ ៨៣៧០ | សារអេឡិចត្រូនិច៖ admin@camclimate.org.kh
គេហទំព័រ៖ www.camclimate.org.kh